# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីទសពិធរាជធម៌១០យ៉ាងសំរាប់ព្រះមហាក្សត្រ
## និងអ្នកកាន់អំណាចជាន់ខ្ពស់ដទៃទៀតប្រតិបត្តិតាម

**web site: hoksavann.org**

ថ្ងៃទី១៦ មករា ២០០៦

មុនព្រះអង្គសំដែងទសពិធរាជធម៌នេះ ភូមិភាគនានានៃពិភពលោក ជាពិសេសទីកន្លែងកំណើតព្រះអង្គ សុទ្ធតែមានស្តេចសោយរាជ្យដាច់ដោយឡែកពីគ្នា ជាភូមិភាគតូចៗរបៀបស្តេចត្រាញ់ ។ ព្រះអង្គយល់ថា ស្តេចដែលកាន់អំណាចទាំងនោះពុំមែនគ្រប់គ្រងប្រជាពលរដ្ឋដោយអំណាចច្បាប់ទេ ច្រើនប្រើអំណាចផ្តាច់ការរបស់ខ្លួន ។ ដោយព្រះបំណងចង់ឲ្យប្រជាពលរដ្ឋរស់នៅក្នុងសុខសន្តិភាព ជៀសវាងការគាបសង្កត់ពីអ្នកកាន់អំណាច ទើបព្រះអង្គសំដែងទសពិធរាជធម៌នេះសំរាប់ឲ្យស្តេចទាំងនោះអនុវត្តតាម ។ ព្រះអង្គប្រកាសថា ទសពិធរាជធម៌១០ប្រការនេះ ធ្វើបុគ្គលដែលប្រតិបត្តិតាមឲ្យទៅជាស្តេច ។ បើមិនប្រតិបត្តិតាមធម៌នេះទេ ពុំអាចធ្វើជាស្តេចដឹកនាំប្រជាពលរដ្ឋបានឡើយ នឹងក្លាយទៅជាបុគ្គលផ្តាច់ការ ជិះជាន់ប្រជាពលរដ្ឋរបស់ខ្លួនពុំខាន ។ ពេលនោះ ព្រះអង្គបានទៅប្រោសព្រះបាទពិម្ពិសារ, ព្រះបាទបសេនទិកោសល ឲ្យប្រតិបត្តិតាមទសពិធរាជធម៌ ឲ្យលុះមគ្គផលនិព្វានផង ។ ទសពិធរាជធម៌១០យ៉ាងនោះគឺ ៖

១- ទាន: ៖ ការធ្វើអំណោយដល់ប្រជាពលរដ្ឋក្រីក្រអត់ឃ្លាននិងខ្វះខាតជាងគេ ដោយសេចក្តីអាណិតអាសូរ ព្រោះព្រះមហាក្សត្រ ជាភ្នែកជាច្រមុះរបស់ប្រជារាស្ត្រ ត្រូវតែដឹងសុខដឹងទុក្ខប្រជារាស្ត្រ ដោយតាំងចិត្តថា សេចក្តីទុក្ខរបស់ប្រជារាស្ត្រ ស្មើនឹងសេចក្តីទុក្ខរបស់ព្រះអង្គ ។ បើប្រជារាស្ត្រអត់ឃ្លាន ក៏រកមធ្យោបាយដោះស្រាយបំបាត់ការអត់ឃ្លាននោះ ។

២- សីល: ៖ រក្សាសីល៥ជានិច្ច មិនសម្លាប់មិនលួចមិនរំលោភយកប្រពន្ធកូនអ្នកដទៃ មិននិយាយកុហក មិនសោយសុរាគ្រឿងស្រវឹង ។ សីល៥នេះជាមូលដ្ឋាននៃសីលធម៌ បានដាក់តម្រូវឲ្យប្រជាពលរដ្ឋនិងព្រះមហាក្សត្រត្រូវតែមានដូចគ្នា ។

បើអ្នកដឹកនាំមិនមានសីលធម៌នេះទេ អាចបៀតបៀនឬសម្លាប់បុគ្គលណាដែលប្រ-ឆាំង, អាចលួចប្រាក់ជាតិជាដើម ។

៣- បរិច្ចាគ: ៖ ការចំណាយព្រះរាជទ្រព្យទំនុកបំរុងប្រទេសនិងឧបត្ថម្ភសាសនា ។ គឺនេះព្រះរាជទ្រព្យមួយភាគជួយស្ថាបនាជាតិ និងឧបត្ថម្ភព្រះពុទ្ធសាសនា សំរាប់បណ្តុះបណ្តាលសីលធម៌ ឲ្យមានវឌ្ឍនភាពទន្ទឹមគ្នានឹងការលូតលាស់ខាងសេដ្ឋកិច្ចជាតិ ។ នៅសម័យពុទ្ធកាល ក្រៅពីការស្ថាបនាជាតិនិងការពារជាតិ ព្រះបាទបសេនទិកោសល ព្រះបាទពិម្ពិសារបានថ្វាយខ្លួនចំពោះព្រះពុទ្ធព្រះធម៌និងព្រះសង្ឃជាញោមឧបដ្ឋាកទំនុកបំរុងព្រះពុទ្ធសាសនាយ៉ាងមុតមាំបំផុត បានជាគំរូដ៏ល្អដល់ប្រជារាស្ត្រទូទៅ ។

៤- អាជ្ជវ: ៖ ប្រែថាមានសេចក្តីត្រង់ គឺមានសេចក្តីទៀងត្រង់ឬស្មោះត្រង់ចំ-ពោះប្រជារាស្ត្រ ។ គ្រប់កិច្ចការដែលអនុវត្តធ្វើ ឬមានបញ្ជាឲ្យអនុវត្តធ្វើ គឺស្របទៅតាមផលប្រយោជន៍របស់ប្រជារាស្ត្រ និងសេចក្តីត្រូវការរបស់ប្រជារាស្ត្រ មិនប្រើល្បិចកិច្ចកលអ្វីមួយទៅលើរាស្ត្រ ដោយព្រះទ័យអកុសលឡើយ ។

៥- មទ្ទវ: ៖ ប្រែថាការទន់ភ្លន់សុភាពរាបសា ទៅកាន់ប្រជារាស្ត្រ គឺមានសេចក្តីរាប់អានប្រជារាស្ត្រទូទៅដូចជាកូនបង្កើត ។ បានសេចក្តីថា មិនប្រកាន់ តែងតែមានការស្និទ្ធស្នាលជានិច្ចទៅលើមនុស្សទូទៅ តែងមានការសន្ទនាដកស្រង់យកយោ-បល់ប្រជារាស្ត្រ ដើម្បីរៀបចំផែនការស្រុកទេសឲ្យមានយុត្តិធម៌ ។ សកម្មភាពបែបនេះតើបឈ្មោះថា ព្រះអង្គដាក់ខ្លួនបំរើប្រជារាស្ត្រដោយស្មោះត្រង់ ។

៦- តប: ៖ ការកាន់ឧពោសថសីលតាមកាលកំណត់ ដើម្បីបន្ថយនូវកាមារម្ម-ណ៍ គឺបន្ថយនូវការសប្បាយក្នុងរូបសម្លេងក្លិនរស និងសម្ផស្ស ធ្វើចិត្តឲ្យស្ងប់ចាកកាមក្នុងថ្ងៃឧបោសថនោះ ព្រោះថា បើអ្នកដឹកនាំរដ្ឋជាន់ខ្ពស់សប្បាយក្នុងកាមខ្លាំងពេក នាំឲ្យរវល់ច្រើនក្នុងកាម ខាតពេលវេលាទៅបំពេញកិច្ចការរដ្ឋ ។

៧- អក្កោធនៈ មិនក្រេវក្រោធ មិនធ្វើឲ្យប្រជារាស្ត្រឬមនុស្សទូទៅក្តៅក្រហាយ គឺរម្ងាប់ក្តីកំហឹងមិនក្រោតតបនូវមនុស្សដែលក្រេវក្រោធ ។

៨- អវិហឹសា ៖ មិនបៀតបៀនប្រជារាស្ត្រនិងមនុស្សទូទៅ គឺមិនធ្វើឲ្យប្រជារាស្ត្រមានទុក្ខដោយផ្លូវកាយនិងផ្លូវចិត្ត តែមានព្រះទ័យករុណាអាណិតអាសូរ ជួយដោះស្រាយគ្រប់បញ្ហាទុក្ខលំបាករបស់ប្រជារាស្ត្រ ។

៩- ខន្តិ ៖ មានការអត់ធន់ចំពោះកិច្ចការលំបាកគ្រប់យ៉ាង និងចំពោះពាក្យរិះគន់គ្រប់បែប ដោយមិនតបតដោយអំពើហឹង្សាឡើយ ។

១០- អវិរោធនៈ ៖ មិនបំពានច្បាប់ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួននិងប្រ-យោជន៍ព្រះញាតិវង្ស មិនរំលោភច្បាប់ព្រះពុទ្ធសាសនានិងច្បាប់រដ្ឋ ។

ទសពិធរាជធម៌ទាំង១០ប្រការនេះ ពុំមែនប្រតិបត្តិតែព្រះមហាក្សត្រទេ អ្នកដឹកនាំរដ្ឋជាន់ខ្ពស់ដទៃទៀតក៏ត្រូវអនុវត្តដែរ ព្រោះរាជៈនេះពុំមែនសំដៅតែព្រះមហាក្សត្រ

ត្រសោយរាជ្យទេ គឺសំដៅយកជនណា ដែលធ្វើឲ្យប្រជារាស្ត្រត្រេកអរបាន គឺត្រេកអរដោយសារមានការធ្វើឲ្យជាតិអភិវឌ្ឍន៍គ្រប់វិស័យ មានវិស័យសេដ្ឋកិច្ច និងវប្បធម៌ជាដើម ។ តាមន័យនេះ ជនណាក៏អាចធ្វើជាព្រះមហាក្សត្របានដែរ ឲ្យតែប្រតិបត្តិឲ្យបានត្រឹមត្រូវតាមទសពិធរាជធម៌ទាំង១០ប្រការនេះ ។ បើប្រតិបត្តិតាមមិនបានទេ មិនអាចធ្វើជាព្រះមហាក្សត្រ ឬអ្នកដឹកនាំរដ្ឋជាន់ខ្ពស់បានទេ ។ ព្រះមហាក្សត្រនិងអ្នកដឹកនាំរដ្ឋជាន់ខ្ពស់ដទៃទៀតចេះតែបាត់បង់ទៅ ដោយសារមិនប្រតិបត្តិតាមទសពិធរាជធម៌ទាំង១០ប្រការនេះឯង ។ ព្រះពុទ្ធសាសនាសំដែងថា ទំនាបនិងកំពស់របស់មនុស្ស ត្រូវស្ថិតនៅលើអំពើអាក្រក់និងអំពើល្អ ដែលគេបានប្រព្រឹត្តធ្វើ ពុំមែនស្ថិតនៅលើជាតិត្រកូល ទ្រព្យសម្បត្តិ យសសក្តិឡើយ ។៚

❑ ❑

❑